ជុះអាចម៍ដាក់កុដិ លួចចង្ហាន់លោកស៊ី ចាក់ដៃលោកគ្រូនឹងស្លាបប៉ាកា រវើរវាយរឿងស្នេហា ជក់មើលល្ខោន ទាស់គ្នាព្រោះដណ្ដើមសំណែនអ្នកតា... ក្មេងវត្តជំនាន់នោះនៅក្នុងកុដិជាមួយគ្នាជាក្រុមៗ។ ពួកគេបរិភោគអាហារពីរពេលក្នុងមួយថ្ងៃ រៀនអាន និងសរសេរអក្សរក្រោមការបង្ហាត់បង្ហាញរបស់ព្រះសង្ឃ ហើយត្រូវតបស្នងសងគុណលោកវិញដោយការគក់ច្របាច់ ពេលលោកឈឺថ្កាត់ និងដាំទឹកប្រគេនលោកជាដើម។ ក្មេងៗរៀនពូកែត្រូវលោកគ្រូបញ្ជូនអោយទៅរៀននៅ«សាលាបារាំង»...

ជីវភាពប្រចាំថ្ងៃព្រមទាំងជីវិតក្មេងវត្តក្នុងខេត្តកំពង់ចាមនាទសវត្សឆ្នាំ១៩៤០ ជាមួយនឹងរឿងរ៉ាវដ៏គួរអោយអស់សំណើចជាច្រើន ត្រូវបានអ្នកនិពន្ធ ជុត ខៃ លើកយកមកបង្ហាញនៅក្នុងរឿង«ក្មេងវត្ត»នេះ។



ជុត ខៃ

# ក្មេងវត្ត សម័យបារាំង



គ្រឹះស្ថានបោះពុម្ពផ្សាយ SIPAR

# ជីវប្រវត្តិ

## អ្នកនិពន្ធ

លោក ជុត ខៃ កើតនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៤០ នៅកោះសំរោង ខេត្តកំពង់ចាម និងបានរៀនដល់ថ្នាក់មធ្យមសិក្សានៅទីនោះ។ ក្រោយបានទទួលសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិនៅវិទ្យាល័យព្រះស៊ីសុវត្ថិ ឆ្នាំ១៩៦២ លោកបានបន្តការសិក្សាផ្នែកនីតិសាស្ត្រនៅក្រុងភ្នំពេញ។ ជាអតីតគ្រូបង្រៀនភាសាបារាំងនិងច្បាប់ ព្រមទាំងជាអ្នកសរសេរអត្ថបទកាសែត លោកមាននាទីជាព្រឹទ្ធបុរសនៅមហាវិទ្យាល័យនីតិសាស្ត្រភ្នំពេញពីឆ្នាំ១៩៧៣ដល់ឆ្នាំ១៩៧៤។ លោកត្រូវបានពួកខ្មែរក្រហមជម្លៀសចេញពីរាជធានីនៅឆ្នាំ១៩៧៥ ដូចប្រជាជនកម្ពុជាដទៃទៀតដែរ ហើយបានភៀសខ្លួនពីប្រទេសកម្ពុជាទៅរស់នៅឯប្រទេសបារាំងនាឆ្នាំ ១៩៨០។ សព្វថ្ងៃនេះ លោករស់នៅទីក្រុងប៉ារីស។

លោក ជុត ខៃ ជាអ្នកនិពន្ធខ្មែរដ៏មានទេពកោសល្យមួយរូបដែលចេះបញ្ចេញគំនិតដោយបញ្ចូលកេរមរតកខ្មែរនិងឥទ្ធិពលពីបស្ចិមប្រទេស។

## វិចិត្រករ

លោក ច័ន្ទ វិត្ថារិន្ទ កើតនៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៥ នៅទីក្រុងភ្នំពេញ។ លោកបានចូលរៀននៅសាលាវិចិត្រសិល្បៈនៅឆ្នាំ១៩៨៦ និងបានទទួលស្លាកប័ត្រសិល្បៈផ្នែកគំនូរបុរាណនៅឆ្នាំ១៩៩២។ បន្ទាប់មកលោកបានទទួលបរិញ្ញាប័ត្រសិល្បៈសូនរូប ផ្នែកវិចិត្រកម្ម និងថតរូបពីសកលវិទ្យាល័យវិចិត្រសិល្បៈនៅឆ្នាំ១៩៩៧។

ជាអ្នកថតរូបនិងជាវិចិត្រករដ៏មានទេពកោសល្យ លោកបានគូរឆាករូបភាពមួយចំនួនសំរាប់កុមារកម្ពុជា។

# វត្តថ្មគោល

**កំទេចព្រះមួយអង្គ ចំណោញស៊ីម៉ងត៍មួយបាវ។**

**(ខ្មែរក្រហម)**

ឆ្នាំ១៩៤៧...

ថ្ងៃមួយនោះ ពូថាបារាំងដើរចាប់ក្មេងឃ្វាលគោ អោយទៅរៀននៅសាលាបារាំង ដោយសារសិស្សចេះតែរត់លូនមិនចង់រៀនសូត្រសោះ។



ក្រោយពីបានព័ត៌មាននេះភ្លាម ឪពុករបស់អាឆៃក៏បញ្ជូនវាអោយទៅនៅវត្តថ្មគោលចំងាយប្រហែល៧គមពីផ្សារកំពង់ចាម និង១គមពីមាត់ទន្លេមេគង្គ។

នៅក្បែររបងវត្ត គេឃើញមានកូនសំណង់តូចមួយ(មិនខុសពីខ្ទមអ្នកតា) ធ្វើអំពីឫស្សី ដំបូលប្រក់ស្បូវ។ សំណង់នេះ គេធ្វើឡើងសំរាប់ការពារថ្មមួយដុំ កុំអោយត្រូវទឹកភ្លៀង រឺកំដៅថ្ងៃ។ ថ្មនោះផុះផុតពីដី មានកំពស់ប្រហែលជាមួយម៉ែត្រ។ ចំណែកក្បាលវាស្រួច មិនខុសពីក្បាលដែកគោលប៉ុន្មានទេ។ អ្នកភូមិ





តែងតែគោរពថ្មនោះ មិនខុសពីគេគោរពអ្នកតាឡើយ។ ដោយសារថ្មនេះហើយ ទើបបានជាគេអោយឈ្មោះវត្តនេះថាជាវត្តថ្មគោល។

វត្តនេះជាវត្តមួយគួរអោយចំលែក ព្រោះលោកសង្ឃដែលគង់នៅទីនោះ ចែកជាពីរគណៈ«អែរម៉ែ» និង«អេរម៉េ» មានន័យថាធម៌បុរាណ និងធម៌សម័យ រឺមានន័យម្យ៉ាងទៀតថា«ថ្មេរសំប៉ែត» និង«ថ្មេរមូល»។ បានជាគេហៅថ្មេរសំប៉ែត ពីព្រោះស្បង់ចីពររបស់លោកសង្ឃធម៌បុរាណមានថ្មេរសំប៉ែត រីឯស្បង់ចីពរលោកសង្ឃធម៌សម័យមានថ្មេរមូល។ មានលក្ខណៈពីរទៀតដែលខុសគ្នា។ ខាងបុរាណ លោកនេនយកស្បង់ចីពរមកគ្រង(យកស្បង់ចីពរមកពាក់នៅលើស្មា រួចយកខ្សែក្រវាត់សំពត់មកចងនៅលើចង្កេះ) រីឯខាងសម័យ លោកនេនឃ្លុំ(យកស្បង់ចីពរមករុំដងខ្លួនជុំជិតខាងលើឃើញតែកនិងព្រះកេស ខាងក្រោមឃើញត្រឹមកំភួនជើងចុះ) នៅពេលលោកនិមន្តទៅបិណ្ឌបាត រឺទៅណាម្តង១។

វត្តមួយសង្ក្រាជ[១]ពីរ មិនខុសពីភ្នំមួយមានខ្លាពីរទេ។ ដល់អ៊ីចឹងទៅលោកសង្ឃក៏មិនសូវត្រូវគ្នា ក្មេងលោកក៏ឈ្លោះគ្នាមិនស្វាង។ មិនត្រឹមតែមនុស្សឈ្លោះគ្នា អាឆ្កែក៏មិនត្រូវគ្នាដែរ។ ឆ្កែខាង«អែរម៉ែ» ឃើញឆ្កែខាង«អេរម៉េ» មិនបានទេ គឺគ្រហឹមខាំគ្នា យកស្លាប់យករស់តែម្តង។

លោកគ្រូសង្ក្រាជខាងធម៌បុរាណមាននាមថា លោកគ្រូអាចារ្យហៃ។ ចំណែកចៅអធិការខាងសម័យមានព្រះនាមថា លោកគ្រូអាចារ្យថោ។

លោកគ្រូសង្ក្រាជទាំងពីរអង្គមានលោកគ្រូសូត្រមួយម្នាក់ៗ។ ការដែលគួរអោយកត់សំគាល់នោះ គឺលោកគ្រូសូត្រទាំងពីរគណៈមានព្រះនេត្រខ្វាក់ដូចៗគ្នា។

អាឆៃ និងខ្ញុំនៅកុដិលោកគ្រូអាចារ្យថៅជាមួយគ្នា។ ក្មេងវត្តខាងអាចារ្យថៅមានទាំងអស់ប្រហែល៣០នាក់។ អាមាឌធំៗ ក្បាលកញ្ចាស់ដូចអាឆៃមាន៥ រឺ៦នាក់។ នៅពេលភ្ជុំបិណ្ឌម្ដងៗ អាឆៃតែងតែនាំក្មេងវត្តអើតករហបនៅលើកុដិដើម្បីអ៊ុតមើលអ្នកទូលនំអន្សម ផ្លែឈើ ម្ហូប-ម្ហាមកប្រគេនលោក ថាតើអ្នកទាំងអស់នោះទៅកុដិអាចារ្យថៅ រឺអាចារ្យហៃ។ បើឃើញអ្នកធ្វើបុណ្យដើរសំដៅមកកុដិអាចារ្យថៅ អាឆៃនិងគូកនវាសប្បាយរីករាយណាស់។ បើឃើញឧបាសក ឧបាសិកាណាដើរសំដៅទៅកុដិអាចារ្យហៃ វាប្រទេចផ្ដាសាថា ជាពួកអា«អែវម៉ែ» បុរាណចាស់គំរិល។

នៅខាងលោកធម៌សម័យ គេឃើញមានកុដិធំៗពីរ គឺកុដិលោកគ្រូសង្ក្រាជនិងលោកគ្រូសូត្រ។ ក្រៅពីកុដិ គេឃើញមានតូប៥ទៀត។ កុដិនិងតូបទាំងនោះសង់អំពីឈើប្រក់ក្បឿង។ លោកសង្ឃខាងសម័យមាន៥០អង្គ ភិក្ខុ១២អង្គ នេន៣៨អង្គ។ កុដិលោកគ្រូអាចារ្យថៅធំជាងគេហើយសង់នៅជិតព្រះវិហារ។ កុដិនេះអាចដាក់មនុស្សបានយ៉ាងតិច១០០នាក់ ព្រោះសាលាឆាន់ សាលារៀនក៏នៅក្នុងកុដិនេះដែរ។ ក្មេងវត្តម្នាក់ៗសុទ្ធតែមានលោកគ្រូបង្ហាត់អក្សរម្នាក់មួយៗ ដែលភាគច្រើនច្រើនតែជានេន។ លោកគ្រូអាឆៃឈ្មោះលោកគ្រូរ៉េត ជាលោកនេនមួយ



អង្គចាស់វស្សាជាងគេ។ ព្រះសង្ឃយកចិត្តទុកដាក់បង្រៀនអក្សរក្មេងៗ ចំណែកក្មេងៗត្រូវតបស្នងសងគុណលោកគ្រូ ដោយដាំទឹកក្ដៅប្រគេនលោក រឺគក់ច្របាច់នៅពេលលោកឈឺថ្កាត់ម្ដងៗ។ ដោយក្មេងៗគ្មានស្លាបព្រាស៊ីបាយ នៅពេលលោកឆាន់រួច លោកគ្រូម្នាក់ៗត្រូវប្រគល់ស្លាបព្រាព្រះអង្គទៅសិស្សរៀងៗខ្លួន។ បើគិតពីរឿងស្លាបព្រា គ្រូនិង



សិស្សមានឋានៈស្មើគ្នា ព្រោះស្លាបព្រាមួយមានម្ចាស់ពីរ។ លោកគ្រូឆាន់រួច សិស្សស៊ីក្រោយ ដល់សិស្សស៊ីរួច លោកគ្រូឆាន់ក្រោយ។ វិលទៅវិលមក មិនដឹងជាសិស្ស រឺលោកគ្រូទេ ដែលបានស្លាបព្រាស៊ី រឺឆាន់បាយមុន។ ស្លាបព្រានេនរ៉េត គ្រូអាឆៃ ធ្វើអំពីស្ពាន់ មានពណ៌លឿង ក្បាលចង់ប៉ុនក្បាលវែក។ លោកគ្រូរ៉េតរអ៊ូរាល់ថ្ងៃ ដោយសារតែអាឆៃវាស៊ីបាយរួចលាងស្លាបព្រាមិនជ្រះ។ យូរៗ អាឆៃយកស្លាបព្រានោះទៅដុសនឹងផេះម្ដង។

វត្តថ្មគោល ជាវត្តមួយសង់នៅលើដីដ៏ធំធេង។ នៅក្នុងវត្ត គេឃើញមានដើមចំប៉ា ដើមត្នោត ដើមបេង និងចំការទៀប។ នៅពេលថ្ងៃសីល



ឈប់សំរាក អាឆៃតែងតែដើររើសបេងទៅអោយម្ដាយវាងកៀនជ្រៃ។ គ្រាប់បេងមានសំបកខ្មៅ ហើយមានប្រយោជន៍សំរាប់អ្នកមូរបារីលក់។ ក្រោយពីយកសំបកវាចេញ គេយកគ្រាប់បេងទៅដុសក្នុងចានថ្ម។ លុះដុសបានបន្តិចមក ទឹកក្នុងចានក្លាយទៅជាខាប់ ប្រហែលនឹងទឹកបាយម៉ានរួចហើយគេយកតម្បារសំឡីជ្រលក់ក្នុងទឹកនោះមកបិទលើក្រដាសជក់មូរបារី។ ម្ដាយអាឆៃគាត់តែងតែមូរបារី មកប្រគេនលោកគ្រូធំជានិច្ចនៅពេលវាបានច្បាប់ទៅលេងផ្ទះម្ដងៗ។

រឿងចំលែកមួយទៀតនៅវត្តថ្មគោល គឺត្រង់ព្រះសង្ឃទាំងពីរគណៈមានបង្គន់រួម។ បើលោកនិមន្តទៅបង្គន់រួមជួបគ្នា ហាក់ដូចជាត្រូវគ្នា តែលោតែជួបគ្នានៅពេលបិណ្ឌបាតវិញ សង្គ្រឹតដាក់គ្នាសឹងតែរបូតស្បង់ចីពរអស់ហើយ។ បង្គន់នោះធ្វើអំពីឈើសង់ខ្ពស់ពីដី ប្រហែល៤ម៉ែត្រ។ បន្ទប់បត់ជើងមានដល់ទៅ១៥ ហើយមានជណ្ដើរឡើងពីរ នៅសងខាងបង្គន់។ ខាងក្រោមទទេស្អាតគ្មានអ្វីបិទបាំងទេ។ ប្រសិនជាអ្នកដំណើរ



ណាម្នាក់វង្វេងផ្លូវដើរទៅក្បែរបង្គន់នោះ ច្បាស់ជាយល់ច្រលំថា មានដំបូក១ដ៏នៅក្រោមសាលាឆាន់ តែតាមពិតគឺគំនរលាមកសោះ ដែលយូរទៅកាន់តែខ្ពស់ឡើងៗសឹងទើសក្ការ។ បង្គន់នេះសង់នៅឆ្ងាយពីកុដិប្រហែល៥០០ម៉ែត្រ តែនៅពេលខ្យល់បក់ខ្លាំងមកម្តងៗ ក្លិនស្អុយជះមកដល់កុដិ សឹងតែដកដង្ហើមមិនរួច។

ចំណែកឯក្មេងៗវិញ គ្មានសំណាងបានទៅបត់ជើងនៅបង្គន់រូមនោះទេ។ វានាំគ្នាទៅលេងឯចំការទៀប។ ចំណែកថ្មនៅក្នុងចំការរលោងដូចបាត្រលោកអស់ទៅហើយ ព្រោះក្រោយពីបត់ជើងរួច វាយកគូទវាទៅកកិតលើថ្ម មិនខុសអ្វីពីសត្វសុនខជុះអាចម៍មានព្រូន អូសគូទវានៅលើដី ព្រោះវារមាស់ក្តិតខ្លាំងពេក។ បើតាមខ្ញុំដឹង ដុំថ្មទាំងនោះបានត្រូវពួកក្មេងវត្តយកធ្វើជាឧបករណ៍ប្រើប្រាស់អស់ជាច្រើនតំណណាស់មកហើយ។

ម្ភៃឆ្នាំក្រោយមក ខ្ញុំជួបអាឆៃនៅភ្នំពេញ វាប្រាប់ខ្ញុំថា វាកើតឫសដូងបាត ព្រោះតែកកិតគូទនឹងថ្ម។ ចៃដន្យអី ខ្ញុំក៏កើតឫសដូងបាតដែរ។ បើដូចនេះ មើលទៅក្មេងវត្តថ្មគោលប្រហែលជាកើតជម្ងឺនេះទាំងអស់គ្នា។

ក្នុងចំណោមក្មេងវត្ត ក្រៅពីអាឆៃ មានពីរបីនាក់ទៀតដែលសុទ្ធតែក្បាល«គ្រាក់ៗ» គឺ អាទិត អាជួន អាជ្រឹង។ អាក្រោយនេះធំដូចឃ្លោកតែរៀនមិនទៅមុខសោះ ហើយរបៀបដូចជាគ្រាសកន្លងផង។ អ្នកមកនៅវត្តស្រករវា គេបួសអស់ទៅហើយ តែអាជ្រឹងមិនទាន់មើលសាស្ត្រាកេរកាលចប់ផង។ មួយថ្ងៃៗ ក្រោយពីឆាន់បាយថ្ងៃត្រង់រួច គេឮតែសម្លេងអាជ្រឹងស្រែកក្តែងៗ : «កេរកាលពីព្រេងព្រិទ្ធ សាងសុចរិតទៀងទុកនៅ សេដ្ឋីផ្តាំប្រដៅ...»។ លោកគ្រូអាជ្រឹង ឈ្មោះលោកគ្រូគង់។

ថ្ងៃមួយ វារៀនប្រកបជាមួយលោកគ្រូវា : «ខ» ដាក់ជើង«ម» «ខ្ម...» «ក» ដាក់ជើង«ម» «ក្ម...»។ លុះដល់ដាក់ជើង«ដ» អាជ្រឹងក៏ស្រែក



ទូលលោកគ្រូវា :



- ទេ តេជគុណ ខ្ញុំកាណា[២]មិនហ៊ានថាទេ តេជគុណ។

- ម៉េច ឯងមិនហ៊ានថា? (លោកគ្រូគង់សួរ)។

- ខ្ញុំកាណាមិនហ៊ានថាទេ តេជគុណ។

- ថាទៅមើល ស្អី?

ដោយលោកគ្រូបង្ខំពេក វាក៏ស្រែកប្រកប«ក» ដាក់ជើង«ដ» «ក្ត»។

- យី អាល្បល់យក៏[៣] អញស្មានថាស្អី។ មើលបន្តទៅទៀតមើ។

អាជ្រឹងបន្តទៅទៀត :

- «ច» ដាក់ជើង«យ» : «ច្យ» ដាក់ស្រះ«ុ» ទេខ្ញុំកាណាមិនហ៊ានថាទេ តេជគុណ។

- យីស្អីទៀតហើយ អាជ្រឹង។ មើ យកមកអោយអញមើលមើ។ លោកគ្រូគង់យកអក្សរមកពិនិត្យ។

- យីអានេះ ចំតែម្តង ឯងមិនឃើញអក្សរ«ត» នៅក្រោយទេរី? អាហ្នឹងអានថា «ចយ៉ុត» (ច្យុត) មិនមែនដូចឯងគិតផ្តេសផ្តាសនោះទេ។ («ច្យុ» សូមអស់លោកអ្នកអានពិចារណាផងទៅចុះ ព្រោះអាហ្នឹងជាអក្សរបុរាណខ្មែរ។ អាជ្រឹងវាគិតទៅរឿងហ្នុងឯង)។

អាជ្រឹងនិងអាជួនស្រករគ្នា តែអាជួនមិនឡប់ៗដូចអាជ្រឹងទេ។ អាជួនមានមាឌធំដំបងដូចក្របីព្រៃ។ វាអុងអាត់ អាន់ជ្រី(អាងយ៉ាង) សម្ពុត

ក្មេងវត្តរាបផ្ទួចកន្ទេល។ អាណាហ៊ានតមាត់នឹងវា វាតប់ វាធាក់ស្រេចនឹងចិត្ត។ តែអាជួនមានចំណុចខ្សោយពីរ : ខ្វាក់មាន់ និងខ្លាចខ្មោច។ អោយតែថ្ងៃលិច អាជួនពិតជារាវ ព្រោះតែមើលមិនឃើញ។ អាឆៃនិងអាជួនមិនសូវត្រូវគ្នាទេ។ អាឆៃមានចរិតស្លូតបូត មិនព្រហើនកោងកាចដូចអាជួនឡើយ។

យប់មួយនោះភ្លៀងផ្គរខ្លាំងណាស់។ យប់ងងឹតចាក់ភ្នែកមិនយល់។ បើគ្មានរន្ទះ យើងពិតជាមើលមេឃមិនឃើញឡើយ។ ដោយសារភ្លៀងខ្លាំង ធាតុអាកាសត្រជាក់ស្រួល ក្មេងវត្តដេកលក់ដូចត្រូវគេសណ្តំ។ លុះព្រលឹមឡើង ស្រាប់តែឮស្ករសំលេងស្រែកឆោឡោថា អាជ្រឹងជុះអាចម៍ដាក់កុដិ។ នៅក្រោមជើងវា គេឃើញអាចម៍មួយចំភ្លុះធំ។ អាជ្រឹងប្រឹងប្រកែកថា មិនមែនវាទេដែលជុះអាចម៍។ អាឆៃក៏វាជឿថា មិនមែនអាជ្រឹងទេដែលជុះអាចម៍ដាក់កុដិ។ គួរកត់សំគាល់ថា ក្មេងវត្តជំនាន់នោះខូចៗណាស់ អាខ្លះខ្លាចខ្មោចពេលយប់ រីក៏ពេលវាភក្រូសម្តងៗ វារត់ចុះពីកុដិមិនទាន់ វាតែងតែទៅបន្ទោបង់នៅក្រោមជើងអាណាដេកលក់ដើម្បីឆ្លើយដាក់គេយករួចខ្លួន។

នៅពេលដែលក្មេងកំពុងតែឆ្លើយដាក់គ្នាពីមួយទៅមួយ លោកគ្រូធំក៏និមន្តមកដល់។

- ម្តេចពួកឯងឡូឡាម្លេះ វាមានរឿងអី? (លោកគ្រូធំមានពុទ្ធដីកា)។

- អាជ្រឹងវាជុះអាចម៍ដាក់កុដិ តេជគុណ! (អាជួនទូលលោក)។

- មិនមែនអាជ្រឹងទេ តេជគុណ(អាឆៃឆ្លើយ)។ ខ្ញុំកាណាឃើញអាជួនក្រោកកណ្តាលយប់ ដើររាវប៉ះជើងគេឯង រួចហើយវាជុះអាចម៍ក្រោមជើងអាជ្រឹង។ អាជួនមុខឡើងស្លាំង ព្រោះវាមានខ្លួន មិនខុសពីពាក្យចាស់លោកថា : «គោដំបៅខ្នង ក្អែកហើររំលង រំសាយកន្ទុយ»។

លោកគ្រូសម្លុតអាជួន :



- អាជួនឯងកុំភូត អញជឿថា ពិតជាឯងហើយ។

អាជួនរញ៉ីរញ៉ូវ និយាយរតិបរតុប។

- ឥលូវ ឯងអោយអញវាយប៉ុន្មានរំពាត់? (លោកគ្រូបន្ត)។

- មិនមែនខ្ញុំកាណាទេ(អាជួនឆ្លើយ)។

- បើអីចឹង អញអោយឯងលូកសំណ![៥]

ឮលោកគ្រូអោយលូកសំណ អាជួនសារភាពកំហុសញាប់មាត់ព្រោះវាខ្លាចសំណជាប់ដៃរហូត។ លោកគ្រូវាយអាជួនលេចនោមជោកខោ។

...ថ្ងៃមួយនោះជាថ្ងៃពេញបូណ៌មី។ នៅពេលល្ងាចក្រោយព្រះអាទិត្យអស្តង្គត អ្នកឡើងត្នោតបីបួននាក់បានរែកទឹកត្នោតជាច្រើនបំពង់មក



ប្រគេនលោក។ ដោយសារថ្ងៃនោះជាថ្ងៃសីល ក្មេងជាច្រើនបានត្រូវលោកគ្រូធំអនុញ្ញាតអោយទៅលេងផ្ទះ នៅសល់តែបីបួននាក់ អាជ្រឹង អាម៉េន អាផៃ អាទិតជាដើម។

ក្រោយពីលោកគ្រូធំចែកចាយទឹកត្នោតទៅលោកសង្ឃឯទៀតរួចរាល់អស់ហើយ លោកក៏មានពុទ្ធដីកាទៅកាន់អាបីបួននាក់នោះថា :

- ឯងនាំគ្នារើសយកបំពង់ទឹកត្នោតតាមដែលឯងស្រលាញ់ទៅចុះ។

អាផៃសប្បាយចិត្តណាស់ ព្រោះវាខានផឹកទឹកត្នោតយូរណាស់មកហើយ។ វាស្ទុះទៅយកអាបំពង់ដែលធំជាងគេមកផឹកសឹងតែមិនដកដង្ហើម។ លុះអស់មួយបំពង់ហើយ អាផៃនៅតែសំលឹងមើលទឹកត្នោតនៅសល់ធ្វើភ្នែកភ្លៀក១។

- ឯងមកយកមួយបំពង់ទៀតទៅអាផៃ(លោកគ្រូធំមានពុទ្ធដីកា) តែប្រយ័ត្នឈឺពោះវើយ។

អាផៃស្ទុះទៅយកមួយបំពង់ទៀត...

រាត្រីខែភ្លឺនៅស្រុកស្រែ។ ខ្យល់បក់រវើយ១ ធ្វើអោយស្លឹកចេកនៅក្បែរកុដិទង្គិចគ្នាឮសូរប្រាវ១។ សំលេងខ្លងខែកឮសូររវើយ១។ នៅកុដិលោកគ្រូធំ ព្រះសង្ឃ និងក្មេង១និទ្រាលក់យ៉ាងស្កប់ស្កល់។ គេឮតែស្នូរសំលេងស្រមុកខុរ១។ លុះដល់ជិតភ្លឺ គេឮសំលេងប្រេសប្រេស១ដូចជាមនុស្សរាវរកអ្វីនៅក្នុងកុដិ។ គួរកត់សំគាល់ថា នៅក្នុងកុដិលោកគ្រូធំក្រោយពីបិទទ្វារដេកនៅពេលយប់ហើយ គឺងងឹតឈឹងតែម្តង។ សំលេងប្រេសប្រេសនេះ គឺជាសំលេងអាផៃវារាវរកទ្វារបើកចេញទៅក្រៅ ព្រោះវារហ័សឈឺពោះចង់បត់ជើងធំ។ ដោយងងឹតផង ឈឺពោះផង អាផៃវង្វេងស៊ុងនៅក្នុងភាពអន្ធការ មិនដឹងណាលិច ណាកើត។ អាផៃវាទប់លែងបានហើយ វាដាច់ចិត្តស្រែកហៅលោកគ្រូវា។

- លោកគ្រូវ៉េតជួយខ្ញុំកាណាផង លេចអាចម៍ដាក់ខោឥលូវហើយ។



អាផៃនិយាយមិនទាន់ចប់ផង ស្រាប់តែឮព្រូស តែវាមានស្មារតីល្អប្រឹងយកដៃទាំងពីរទៅក្របួចជើងខោជាប់។ លោកគ្រូវ៉េតគូសដែកកេះឆឹក១ ស្រាប់តែឃើញអាផៃនៅក្នុងភាពទាល់ច្រក បែរមុខទៅទល់ជញ្ជាំង។ លោកគ្រូប្រឹងទៅបើកទ្វារ។

- អាល្បល់យក៏(លោកគ្រូជេរ) អញប្រាប់តាំងពីក្បាលល្ងាចម្ល៉េះថា កុំអោយឯងផឹកទឹកត្នោតច្រើនពេក ឯងមិនជឿអញ។

អាផៃប្រឹងក្របួចជើងខោទាំងពីរមែន ប៉ុន្តែវត្ថុរាវហូរតាមជើងខោប្រលាក់ទាំងក្តារ ប្រលាក់ទាំងជញ្ជាំងកុដិ ជះក្លិនស្អុយស្ទើរប្រកាច់។ ក្មេងក្មាង លោកនេន លោកភឹក ផ្អើលឆោឡោស្មានតែភ្លើងឆេះកុដិ មិននឹកស្មានថា អាផៃរាកអាចម៍ដាក់ខោសោះ។ អាផៃស្ទុះទៅដល់អណ្តូងខំលាងប្រាណវា ហើយគ្រវាត់ខោចោលនៅគុម្ពចេកបាត់។ វាខំរែកទឹក២០អំរែកមកលាងក្តារនិងជណ្តើរ តែទោះជាខំលាងយ៉ាងណា ក៏នៅតែធំក្លិនស្អុយ។ លោកគ្រូធំហួសចិត្ត អស់ពីខ្វាល់ទៅជាសើច។

ក្មេងវត្តបរិភោគបាយពីរដងក្នុងមួយថ្ងៃ គឺថ្ងៃត្រង់ក្រោយពីលោកឆាន់រួច និងពេលល្ងាច។ ជួនកាល ល្ងាចខ្លះឥតមានសល់បាយ ត្រូវដេកអត់ទៅ។ នៅពេលលោកឆាន់ត្រង់ ក្មេង១ឃ្លានបាយខ្លាំងណាស់ អាខ្លះកូរពោះដូចឆ្កែខែកត្តិក។ ម្នាក់១អង្គុយបត់ជើងនៅមុខលោក ចាំស្តាប់តែធម៌«យថា»(អានថាយាក់ថា) ព្រោះថាបើលោកឆាន់បាយរួច លោកសូត្រធម៌នេះដើម្បីឧទ្ទិសផលបុណ្យទៅដល់ម្ចាស់បុណ្យ។ ធម៌នេះខ្ញុំចាំរត់មាត់ទាល់តែសព្វថ្ងៃ ព្រោះមួយថ្ងៃ១ ខ្ញុំខំផ្ទៀងត្រចៀកចាំតែស្តាប់ធម៌ហ្នឹងឯង :

**យថាវារិវហារ បូរា បរិបូរេន្តិ សាគរំ** ផ្លូវទឹកទាំងឡាយ មានទន្លេនិងស្ទឹងជាដើម ដ៏ពេញដែលញុាំងសាគរ គឺសមុទ្រអោយពេញប្រៀបដូចម្តេចមិញ។



**ឯវមេវ ឥតោ ទិន្នំ បេតានំ ឧបកប្បតិ** ទានដែលទាយក ទាយិកាឧទ្ទិសអោយហើយ អំពីលោកនេះរមែងសំរេចផលដល់អ្នកដែលចែកស្ថានទៅកាន់បរលោកហើយផ្ទុច្នោះឯង។

**ឥច្ឆិតំ បត្ថិតំ តុម្ហំ ខិប្បមេវ សមិជ្ឈតុ** សូមឥដ្ឋផល គឺផលជាទីគាប់ចិត្ត ដែលអ្នកប្រាថ្នាហើយ តាំងចិត្តហើយ ចូរអោយសំរេចដល់អ្នកអោយឆាប់រួសរាន់ទាន់ចិត្ត...

លុះលោកសូត្រចប់ ទើបក្មេងវត្តសូត្រធម៌យំកិញ្ចិ«យំកិញ្ចិ កុសលកម្មំ...»។ ផល់យំកញ្ចិចប់ ទើបបានបាយស៊ី។

ក្មេងវត្តបរិភោគបាយ ដោយនាំគ្នាអង្គុយចោងហោងជារង្វង់មូល។ នៅពេលស៊ីបាយនោះទៀត ពួកអាធំៗ វាអុងអាត់ធ្វើបាបពួកអាតូចៗ ដោយប្រើវិធីខ្ទចម្យ៉ាង គឺលួចញាត់ម្ទេសក្នុងប្រហោងដើមត្រកួន។ អាណាស៊ីចំ វាលោតកញ្ឆក់កញ្ឆែង លែងស៊ីបាយកើត។ បើមិនលួចញាត់ម្ទេស វាប្រើវិធីម្យ៉ាងទៀត ដែលគេហៅថា«សម្លហោះ»។ អាសម្លហោះនេះ ពួកអាធំៗវាហុចចានសម្លពីលើក្បាលអាតូចៗទៅអោយពួកអាធំៗគ្នាវា ទាល់តែវាហុតសម្លអស់ពីចាន ទើបវាដាក់ចានចុះ។



រដូវភ្ជុំបិណ្ឌ ជារដូវសម្បូណ៌សប្បាយ។ ក្មេងវត្តដេកចាំតែរដូវនេះឯង ព្រោះវាមិនបាច់ដើរទៅយកវេន(ពាក្យថាយកវេន គឺទៅយកម្ហូបម្ហានៅផ្ទះឧបាសក ឧបាសិកា ដែលត្រូវវេនធ្វើម្ហូបប្រគេនលោក) នាំអោយហេវហត់។ ម្ហូបម្ហាសម្បូណ៌ហូរហៀរ។ ពុទ្ធសាសនិកស្រីប្រុសទូល រែកបាយសម្ល នំនែកមកប្រគេនលោកដល់កុដិ។ នំបត់ នំគម នំក្រពងនំកន្ត្រំ ជាពិសេសនំអន្សមចេក និងអន្សមជ្រូកគរដូចភ្នំ។ តែរដូវនេះក៏ជារដូវដែលក្មេងវត្តវាភាក្សួស និងជុះអាចម៍ដាក់កុដិដែរ។ ម្នាក់ៗខំប្រឹងស៊ីនំអន្សមចេក អន្សមជ្រូក ដើម្បីសងនៅពេលអត់។ អាខ្លះរត់មិនទាន់លេងតែក្រោមជើងគ្នាវា អាខ្លះទៀតវាភាកដាក់កាំជណ្តើរ-ល-។

ដើម្បីកុំអោយអន្សមផ្អូម ព្រះសង្ឃលោកធ្វើរានអំពីឫស្សីសំរាប់ផ្ដើរអន្សម រួចហើយចាត់ពួកអាគ្រាក់ៗអោយចាំយាមភ្លើង។ ពេលយប់ពួកអាក្បាលកញ្ចាស់ដែលត្រូវយាមភ្លើងអន្សម វាតែងតែសម្លុតពួកអាតូចៗអោយយាមភ្លើងអន្សមជំនួសវា។ យប់មួយនោះ ចំពេលអាឡាក់



មេអុងអាត់យាមអន្សម។ នៅពេលងងុយដេក វាទៅដាស់ខ្ញុំនិងអាម៉ែនអោយមកយាមជំនួសវា។ លុះអង្គុយយាមភ្លើងបានមួយសន្ទុះធំ យើងទាំងពីរនាក់ក៏ដេកលង់លក់ទៅហោង។ មិនដឹងជាចៃដន្យអី ស្រាប់តែភ្លើងឆេះរានឆ្អើរអន្សម។ អន្សមមួយរានក៏ក្លាយទៅជាធ្យូងស្ទើរតែទាំងអស់។ លុះព្រឹកឡើង លោកគ្រូធំសួរទៅអាឡាក់ :

- អាឡាក់ យប់មិញ អញអោយឯងយាមភ្លើងអន្សម ហេតុដូចម្ដេចបានជាភ្លើងឆេះរានឆ្អើរអន្សម?

អាឡាក់អេះអុញៗ មិនហ៊ានទូលលោកថា វាចាត់ខ្ញុំនិងអាម៉ែនអោយយាមភ្លើងអន្សមជំនួសវា។ លោកគ្រូវាយអាឡាក់ ប្រហែល២០រំពាត់។ ខ្នងវាឡើងក្រហមដូចគេកោសខ្យល់។ ខ្ញុំ និងអាម៉ែននាំគ្នាលួចសើចនៅក្រោមកុដិ។ ពេលល្ងាច នៅពេលទៅដងទឹកឯទន្លេ អាឡាក់វាធាក់ខ្ញុំ និងអាម៉ែនបីបួនជើង។ តែទោះជាយ៉ាងម៉េច ក៏ខ្ញុំអស់ចិត្តដែរ ព្រោះលោកគ្រូធំវាយវាធ្ងន់ដៃណាស់។







# កុងប៉ាង

### ចង់អោយលុយដែរ តែខុសវត្តគ្នា...

ផ្លូវចូលទៅវត្តថ្មគោលចាប់ផ្ដើមពីមាត់ទន្លេរហូតទៅដល់ជណ្ដើរព្រះវិហារ។ ផ្លូវនេះចាក់ស៊ីម៉ងត៍ មានប្រវែងប្រហែលមួយគីឡូម៉ែត្រ ទទឹងពីបីទៅបួនម៉ែត្រ។ នៅក្បែរដើមផ្លូវ គេឃើញមានស្ពានឈើដ៏កញ្ចាស់កំព្រូកមួយសង់កាត់អូរ ដែលមានទឹកហូរយ៉ាងត្របាញ់ទៅបំពេញបឹងដ៏ធំនៅពេលទឹកឡើង។ បន្ទះក្ដារខ្លះពុករលួយធ្លាក់ទៅក្នុងទឹក បន្ទះក្ដារខ្លះទៀតឃ្លាតចេញពីគ្នាឃើញតែក្បាលឡោស៊ីអោយរពុយ។ អ្នកដើរលើស្ពាន បើមិនប្រយ័ត្នពិតជាធ្លាក់ទៅក្នុងទឹក រឺក៏ជាន់ក្បាលឡោស៊ី។ មិនមែនតែស្ពានវត្តថ្មគោលទេ ដែលខ្វះក្ដារយកមកផ្លាស់ ស្ពានដទៃទៀតនៅតាមមាត់ទន្លេក៏មានសភាពដូចគ្នាដែរ។

បីភាគបួននៃប្រទេសខ្មែរកាលជំនាន់នោះ  ពោរពេញទៅដោយព្រៃឈើៗ តែសូមទោស ខ្មែរយើងពុំមានឈើធ្វើស្ពានអោយបានត្រឹមត្រូវមាំមួនឡើយៗ

ឱស្ពានដីកំសត់អើយ!

គឺជារដូវវស្សា  ទន្លេមេគង្គបានក្លាយទៅជាសមុទ្រដ៏តូចមួយនៅក្នុងស្រុកខ្មែរៗ ទឹកហូរចូលព្រែក បឹងបួគ្រប់ទិសទីៗ

ផ្លូវចូលទៅវត្តលិចទឹកត្រឹមភ្នែកគោលៗ  មនុស្សម្នាជាច្រើននាំគ្នាត្រងកូនត្រីយកទៅធ្វើផ្អកត្រីភ្អិតនៅសងខាងផ្លូវ  ដោយប្រើទ្រូ  ឈ្នាងប្រឌីសឬស្សី-ល- ធ្វើជាឧបករណ៍នេសាទៗ ក្នុងមួយប៉ប្រិចភ្នែក  គេត្រងកូនត្រីបានកន្លះកញ្ជើៗ

ឱស្រុកយើងអើយសម្បូណ៌ត្រីអ្វីម្ល៉េះទេ!

មានទឹក មានត្រី!

នៅពេលខ្ញុំកំពុងរត់លេងយ៉ាងសប្បាយនៅលើផ្លូវទឹកលិច  ខ្ញុំឃើញតាចាស់ម្នាក់ស្ពាយថង់យាមដើរក្បែរខ្ញុំៗ   ខ្ញុំស្គាល់គាត់ច្បាស់ណាស់ព្រោះគាត់ត្រូវជាប្អូនពៅជីដូនខ្ញុំៗ តាចាស់នោះឈ្មោះប៉ាងៗ

ខ្ញុំស្ទុះទៅជំរាបសួរគាត់ៗ

- ជំរាបសួរកុង(តា)ៗ
- តើឯងជាកូនចៅពីណា?
- ម្តាយខ្ញុំឈ្មោះលី ឪពុកខ្ញុំឈ្មោះគ្រុយ កុង!
- អ្ហ៎! ឯងកូនកាលី ទេតើៗ ឯងចេះគួរសម រាក់ទាក់ល្អណាស់ៗ



នៅពេលនិយាយ គាត់លូកដៃទៅក្នុងថង់យាម ហើយដកលុយមួយរៀលមកកាន់នៅដៃស្តាំបំរុងនឹងហុចអោយខ្ញុំ។ តែមុននឹងអោយ កុងប៉ាងសួរខ្ញុំតទៅទៀត។

- ឯងនៅកុដិណា?

- ខ្ញុំនៅកុដិអាចារ្យចៅ កុង!

ឮតែអាចារ្យចៅ គាត់ដាក់លុយទៅក្នុងថង់វិញបាត់ រួចនិយាយរបៀបខឹងមកកាន់ខ្ញុំ :

- យីមីកាលី ហេតុដូចម្តេចបានជាវាយកកូនមកអោយនៅកុដិអាចារ្យចៅអីចឹង?

និយាយរួចគាត់ដើរចូលទៅក្នុងវត្តរបៀបតយង៉យ។ ចំណែកខ្ញុំដែលប្រឹងសប្បាយចិត្តថា នឹងបានលុយមួយរៀលនោះ ទៅជាស្រឡាំងកាំងខកចិត្ត គិតមិនយល់ពីអាកប្បកិរិយាកុងខ្ញុំសោះ។ កុងប៉ាងធ្វើបុណ្យខាងអាចារ្យហៃធម៌បុរាណ គាត់មិនសប្បាយចិត្តនឹងអ្នកណា ដែលធ្វើបុណ្យខាងសម័យនោះទេ។ ជាពិសេសចំលើក្មួយស្រី(ម្តាយខ្ញុំ) របស់គាត់តែម្តង។ បើខ្ញុំឆ្លើយថា ខ្ញុំនៅកុដិអាចារ្យហៃ គាត់ពិតជាមិនដាក់លុយចូលទៅក្នុងថង់វិញទេ។

នេះហើយចរិតខ្មែរ : ប្រកាន់ និងមានះ។ បើឯងកាន់ធម៌សម័យ អញធម៌បុរាណ ឯងនិងអញជាសត្រូវនឹងគ្នា។ បើអញសង្គមរាស្ត្រនិយម ឯងប្រជាធិបតេយ្យ អញនិងឯងជាសត្រូវស្លាប់រស់នឹងគ្នា។ បើឯងមិនមែនខ្មែរក្រហម អញមានអំណាច អញសំលាប់ឯងចោល។

មនុស្សខ្មែរ សង្គមខ្មែររបៀបនេះហើយដែលស្រុកខ្មែរយើងចេះតែរួមតូចទៅៗ ហើយមនុស្សខ្មែរក៏រឹតតែតិចទៅៗ...



# វត្តវិហារទន្ទឹម

### ថ្វាយបង្គំព្រះ ដូចថ្វាយបង្គំស៊ីម៉ងត៍ ព្រះកើតមកពីជាងកំបោរ លោកសង្ឃជាបញ្ចើក្អែក និងព្រួនសង្គម។

(ខ្មែរក្រហម)

យើងចូលមកដល់ឆ្នាំ១៩៤៨។

ប្រាំពីរខែហើយ ដែលខ្ញុំមកនៅវត្តថ្មគោលជាមួយនឹងអាឆៃ។ ព្រះសង្ឃដែលបង្រៀនអក្សរខ្ញុំមិនមែនលោកគ្រូធំទេ គឺលោកគ្រូសូត្រស្តាំព្រះនាមផេត។ ព្រះសង្ឃអង្គនេះពូកែអក្សរសាស្ត្រ តែអកុសលត្រង់ព្រះនេត្រលោកខ្វាក់ទាំងសងខាង។ សំលេងលោកក៏ពីរោះ ហើយពូកែទេសនា។ ពួកពុទ្ធសាសនិកជើងវត្តប្រសិទ្ធនាមថា លោកគ្រូអាចារ្យផេត។ លោកដូចជាមាននិស្ស័យនឹងខ្ញុំ ព្រោះលោកយកចិត្តទុកដាក់បង្ហាត់បង្ហាញខ្ញុំច្រើនជាងគេ។ ព្រះអង្គចូលចិត្តហៅខ្ញុំថាកូនៗ។ ថ្ងៃមួយនោះ លោកហៅខ្ញុំទៅប្រាប់ :

- កូនឯងត្រូវទៅរៀនសាលាបារាំងនៅឯសួង ហើយស្នាក់នៅវត្តព្រះវិហារទន្ទឹម។ លោកគ្រូបានផ្តាំផ្ញើនឹងលោកគ្រូធំវត្តវិហារទន្ទឹមរួចអស់ហើយ។ លោកគ្រូចង់អោយឯងទៅរៀនសាលាបឋមសិក្សានៅឯទីក្រុងកំពង់ចាមដែរ តែសាលានៅឆ្ងាយពីវត្តណាស់ ឯងពិតជាដើរមិនដល់ទេ។ ចំណែកសាលាបារាំងនៅសួងវានៅជិតវត្តវិហារទន្ទឹម។

- ខ្ញុំកាណា សូមលោកគ្រូអនុញ្ញាតអោយអាម៉េនវាទៅជាមួយផង គ្រាន់បានជាគ្នា។

- មិនបាច់ទេ អាម៉េនត្រូវរៀនធម៌បួស។ ឯងត្រូវរៀនភាសាបារាំង ដើម្បីធ្វើចិថុងនឹងគេ។

មិនដឹងជាចៃដន្យអីលោកគ្រូអាចារ្យវិញ សង្គ្រាជវត្តវិហារទន្ទឹមនិមន្ត មកវត្តថ្មគោល។ ខ្ញុំក៏ធ្វើដំណើរទៅតាមលោកតែម្តង។ ដោយខ្ញុំចេះមើលអក្សរដាច់ត្រឹមត្រូវ លោកចាងហ្វាងសាលាបឋមសិក្សាសួងអោយខ្ញុំចូលរៀនថ្នាក់បរិវច្ឆ័ណដ្ឋានតែម្តង(បច្ចុប្បន្នគឺថ្នាក់ទី២)។

ចំពោះខ្ញុំ សួងពិតជានៅឆ្ងាយពីកោះសំរោង ពីវត្តថ្មគោល។ ខ្ញុំបែកពីអាម៉េន ពីអាឆៃ ពីលោកគ្រូ។ ខ្ញុំកំសត់តែម្នាក់ឯង។ ខ្ញុំនឹកស្រុក ជាពិសេសនឹកម្តាយខ្ញុំតែម្តង។ អ្វីៗនៅជុំវិញខ្ញុំ ហាក់ដូចជាប្លែកខុសប្រក្រតី។ ខ្ញុំធ្លាប់តែរស់នៅតាមមាត់ទន្លេ ធ្លាប់តែឃើញដើមស្វាយ ដើមគ ចំការថ្នាំ ចំការពោត។ លុះមកនៅវត្តវិហារទន្ទឹម ទេសភាពខុសប្លែកពីនៅមាត់ទន្លេ។ ខ្ញុំឃើញតែដើមត្នោតដុះពាសពេញក្នុងវត្ត ដើមថ្កូវ ដើមជើងចាប



ដែលមានផ្លែដូចកញ្ចុំជើងចាប ហើយដែលគេអាចបរិភោគបាន និងវាលស្រែដ៏ធំធេងមើលដាច់កន្ទុយភ្នែក។ រឿងដែលប្លែកម្យ៉ាងទៀត គឺរបងវត្តវិហារទន្ទឹមនៅជាប់នឹងផ្សារសួងតែម្តង។ ផ្សារនេះអ៊ូអរខ្លាំងណាស់ដែរ មិនចាញ់ផ្សារកំពង់ចាមប៉ុន្មានទេ។ វត្តសួងមានវិហារពីរ វិហារទីមួយមានមកជាយូរឆ្នាំណាស់មកហើយ។ ចំណែកវិហារទីពីរនៅទន្ទឹមនឹងវិហារទីមួយ ឃើញតែឃឿន។ មើលទៅប្រហែលជា



ឧបាសក ឧបាសិកាជើងវត្តខ្វះបច្ច័យហើយបានជាទុកវិហារទីពីរអោយនៅខ្វាយដូច្នេះ។ ដោយសារវត្តនេះមានវិហារពីរនៅទន្ទឹមគ្នា ទើបមានឈ្មោះថា វត្តវិហារទន្ទឹម។

នៅមុខវិហារប្រហែល២០០ម៉ែត្រ គេឃើញខ្ទមអ្នកតាមួយសង់នៅក្រោមដើមពោធិ៍។ ខ្ទមអ្នកតានេះមិនមែនរខេករខាកទេ។ ដំបូលប្រក់ក្បឿងពណ៌ប្រផេះ ជញ្ជាំងព័ទ្ធទៅដោយក្តាររឹងមាំ កម្រាលក្រាលដោយស៊ីម៉ងត៍។ រូបអ្នកតាថ្មមួយអង្គុយគ្រហើៗនៅលើអាសនៈស៊ីម៉ងត៍។ ខ្ទមនេះបែរមុខទៅទិសខាងកើត ហើយនៅស្របនឹងបឹងមួយដែលសំបូរទៅដោយត្រីនិងអណ្តើក។ មច្ឆាទាំងនេះរស់ទៅដល់ថ្ងៃស្លាប់គ្មាននរណាហ៊ានប៉ះពាល់វាទេ ព្រោះវាជាគរុភណ្ឌ(ទ្រព្យរបស់ព្រះសង្ឃ)។ សឹងតែរៀងរាល់ថ្ងៃ ចិនៗតែងតែមកសែនអ្នកតា។ មកនៅវត្តសួងបានប៉ុន្មានថ្ងៃ ខ្ញុំមានពួកម៉ាកម្នាក់ទៀតឈ្មោះអារ៉េត។ អារ៉េតចូលចិត្តនាំខ្ញុំទៅខ្ទមអ្នកតាណាស់ដើម្បីយកសំណែន នៅពេលដែលចិនៗត្រលប់ទៅផ្ទះវិញ។ ក្រៅពីអារ៉េតនិងខ្ញុំ មានក្មេងៗបីបួននាក់ទៀត ក៏នាំគ្នា



ទៅទីនោះដែរ។ ជួនកាល ក្មេងៗវាយគ្នាពេញតូប ដើម្បីដណ្ដើមយកសំណែន។ ដោយឃើញក្មេងរញ៉ីរញ៉ៃពេក ចិនៗក្រោយពីសែនរួច ក៏យកសំណែនដាក់ក្នុងកញ្ជ្រែងដើរទៅផ្ទះធ្វើវាហ៊ី។ ក្មេងៗនាំគ្នារអ៊ូរទាំជេរម្រាយ(ជេរម្ដាយ) ចិនមិនឈប់ឈរ។ ថ្ងៃមួយ ខ្ញុំនិយាយទៅអារ៉េត :

- បើចិនមិនទុកសំណែនទេ យើងគិតសែងអ្នកតាទំលាក់ក្នុងបឹង រឺយ៉ាងម៉េចអ្នា?

- ទេ អញខ្លាចអ្នកតា«ធើ» ណាស៊ីុយ(អារ៉េតឆ្លើយ)។

- ពេលយើងសែងអ្នកតាទំលាក់ទឹក ឯងកុំសើច ព្រោះអញឮចាស់ៗនិយាយថា បើយើងមិនសើច អ្នកតាឥត«ធើ» ទេ។

មែន ព្រឹកមួយនោះ ខ្ញុំនិងអារ៉េតសែងអ្នកតាបោះក្នុងទឹកប្រុង។ ចិនរកអ្នកតាមិនឃើញ ក៏នាំគ្នាជេរស៊ីុយម៉ែ! ស៊ីុយម៉ែ!... អារ៉េតនិងខ្ញុំនាំគ្នាសើចគិល។ ចិនយល់ស្ថានការណ៍ ក៏អង្វរពួកយើងអោយលើកអ្នកតាមកដាក់កន្លែងដើមវិញ។ ចាប់តាំងពីថ្ងៃនោះមក ចិនទុកសំណែនរហូត។ ថ្ងៃមួយនោះ មិនដឹងជាចង្រៃអី នៅពេលដែលខ្ញុំកំពុងដណ្ដើមបានដូងមួយ ស្រាប់តែធូបដែលគេដុតហើយដោតនៅលើដូងវាវាត់មកប៉ះថ្ពាល់ស្ដាំខ្ញុំផាច់។ ថ្ពាល់ខ្ញុំឡើងក្រហម រួចមកក្លាយទៅជាដំបៅរហូតមានស្លាកស្នាមមកដល់សព្វថ្ងៃនេះ។

- អ្ហែងឃើញទេ(អារ៉េតនិយាយ) អ្នកតាអត់«ធើ» អ្ហែងទេ តែអ្នកតាសងសឹក។

ខ្ញុំខឹងនឹងអ្នកតាឡើងញ័រខ្លួន។ នៅពេលស្ងាត់ឥតមានចិនមកសែនខ្ញុំស្ទុះទៅវាយក្បាលអ្នកតាផាច់ចេញពីខ្លួន ហើយយកទៅគ្រវាត់ចោលទៅក្នុងបឹងបាត់។

តាមពិត កាលខ្ញុំមករៀនសាលាបារាំងនៅស្ទួង ខ្ញុំដូចជាមិនខ្សត់ប៉ុន្មានទេ។ នៅពេលវាកងទៅផ្ទះម្ដងៗ ខ្ញុំតែងតែឆៀងចូលទៅវត្ត



ថ្មគោលដើម្បីថ្វាយបង្គំលោកគ្រូខ្ញុំ។ នៅពេលជួបលោកម្ដងៗ លោកបានអោយលុយខ្ញុំយ៉ាងតិច៥រៀល។ ចំណែកម្ដាយខ្ញុំ ក៏អោយខ្ញុំយ៉ាងតិច២០រៀលដែរ កាលជំនាន់នោះ។

ដោយសារការធ្វើដំណើរតាមទូកដ តាមឡានឈ្នួលឥតគិតលុយ «ជិះទទេ» ពីទន្លេបិទមកស្ទួង លុយដែលខ្ញុំមានទាំងប៉ុន្មាន នៅសល់ទាំងអស់។ តែរឿងជិះឡានទទេ គួរអោយចង់សើច ព្រោះខ្ញុំត្រូវជិះជាមួយមាន់ ទា ជ្រូក ក្ងាន។ ឡានឈ្នួលទន្លេបិទ-ស្ទួងជំនាន់នោះខុសប្លែកពីឡានឈ្នួលឯទៀតៗ។ បើខ្ញុំមិនច្រឡំទេ បែបមានតែឡានហ្នឹងទេដែលរត់ពីស្ទួងមកទន្លេបិទ ពីទន្លេបិទទៅស្ទួង។ ឡាននោះចែកជាពីរផ្នែក មួយផ្នែកធំវែងសំរាប់ដាក់អ្នកដំណើរ មួយផ្នែកទៀតនៅខាង

